**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ភាគីដាក់ឯកសារ៖ | សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី |
| ដាក់ជូន៖ | អង្គជំនុំជម្រះតុលាការកំពូល |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ |

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 28-Apr-2023, 09:10
CMS/CFO: Sann Rada

---

**របាយការណ៍ចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្ដីពីសំណង នៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Falguni DEBNATH

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

Laure DESFORGES
Isabelle DURAND
Emmanuel ALTIT
Martine JACQUIN
Daniel LOSQ
Christine MARTINEAU

<u>នៅចំពោះមុខ</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ឹម ប្រធាន

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MWACHANDE- MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ឡោ ជុនធី
ម៉ុច សុវណ្ណារី
ស៊ិន សុវ៉ន
សំ សុគង់
វ៉ែន ពៅ
ទី ស្រ៊ីនណា

Lyma NGUYEN
Mahesh RAI
Nushin SARKARATI

ចៅក្រម Phillip RAPOZA
ចៅក្រម យ៉ា ណារិន

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង

Fergal GAYNOR (បម្រុង)

**ជនជាប់ចោទ៖**

ខៀវ សំផន

**សហមេធាវីការពារក្តី៖**

គង់ សំអុន
Anta GUISSÉ

# ១. សេចក្ដីផ្ដើម

1. សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (“សហមេធាវីនាំមុខ”) បានដាក់សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួនក្នុងសំណុំរឿង០០២/០២ កាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ ក្នុងនោះបានបង្ហាញទិដ្ឋភាពរួមនៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២/០២ និងបានបង្ហាញព្យសនកម្មទទួលរងដោយដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[1]។ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ សហមេធាវីនាំមុខ បានដាក់បណ្ដឹងទាមទារចុងក្រោយនៅក្នុងសំណុំរឿង ០០២/០២ (“បណ្ដឹងទាមទារចុងក្រោយ”) ដោយបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់គម្រោងចំនួន១៨ តាមផ្លូវតុលាការសម្រាប់ជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះព្យសនកម្មកើតចេញពីឧក្រិដ្ឋកម្មដែលត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២[2]។ បន្ទាប់មក សហមេធាវីនាំមុខ បានដាក់សេចក្ដីសន្និដ្ឋានបន្ថែមដោយបានផ្ដល់ ភ័ស្ដុតាងមូលនិធិសម្រាប់គម្រោងសំណងមួយចំនួន និងបានដកគម្រោងសំណងខ្លះដោយសារពុំអាចរកមូលនិធិគាំទ្របាន[3]។

2. វិធាន ២៣*ស្ទួនបួន* ចែងអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការទាមទារសំណងសមូហភាព និងផ្លូវចិត្ត ចំពោះការខូចខាតដែលពួកគេបានទទួលរងដោយសារលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបានជំនុំជម្រះ។ តុលាការអាចបង្គាប់ឱ្យសងសំណងតែក្នុងករណីដែលជនជាប់ចោទត្រូវបានផ្ដន្ទាទោស ហើយសំណងត្រូវផ្ដល់ប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីជួសជុលការខូចខាត ដែលបានទទួលរង។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងព្យសនកម្មដោយសារអំពើ ដែលត្រូវបានផ្ដន្ទាទោសលើ ខៀវ សំផន និង នួន ជា ហើយបានសម្រេចផ្ដល់

---

[1] ឯកសារ E457/6/2 សារណាបញ្ចប់ការពិភាក្សាដេញដោលរបស់សហមេធាវីនាំមុខក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧។

[2] ឯកសារ E457/6/2/1 បណ្ដឹងទាមទារចុងក្រោយរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់សំណងនៅក្នុងសំណុំរឿង ០០២/០២ ភ្ជាប់ជាមួយឧបសម្ព័ន្ធសម្ងាត់ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧។

[3] ឯកសារ E457/6/2/4 សេចក្ដីសន្និដ្ឋានបន្ថែមរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីបញ្ហាមូលនិធិពាក់ព័ន្ធនឹងគម្រោងសំណងនៅក្នុងសំណុំរឿង ០០២/០២ និងសំណើសុំគោលការណ៍ណែនាំជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧។

សំណងមួយផ្នែកទៅតាមសំណើសុំសំណងផ្លូវចិត្ត និងសមូហភាព ដោយអង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់គម្រោងសំណងចំនួន១៣គម្រោង[4]។

3. អាស្រ័យហេតុនេះ សហមេធាវីនាំមុខ សូមដាក់របាយការណ៍ចុងក្រោយស្តីពីសំណងក្នុងសំណុំរឿង ០០២/០២ ដើម្បីជូនដំណឹងដល់អង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") អំពីស្ថានភាពនៃការអនុវត្តគម្រោងសំណងចំនួន១៣ ដែលត្រូវបានទទួលស្គាល់។ ព័ត៌មានលម្អិតអំពីគម្រោងសំណងមានភ្ជាប់ជាមួយរបាយការណ៍នេះ ជាឧបសម្ព័ន្ធសម្ងាត់ ព្រមទាំងសារណាមុនៗ រួមទាំង បណ្តឹងទាមទារចុងក្រោយ។ ដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នាជាមួយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០២ ឧបសម្ព័ន្ធសម្ងាត់ត្រូវតែរក្សាជាការសម្ងាត់ដដែល[5]។

## ២. របាយការណ៍ស្តីពីស្ថានភាពនៃការអនុវត្តគម្រោងសំណងដែលត្រូវបានទទួលស្គាល់

### *២.១. គម្រោងទី១៖ App-Learning on Khmer Rouge History អេបសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម*

4. មជ្ឈមណ្ឌលធនធានសោតទស្សន៍បុប្ផាណា ដោយសហការជាមួយ សហមេធាវីនាំមុខ អង្គភាពគាំពារជនរងគ្រោះ និងដៃគូសំខាន់ៗ បានរចនា និងអនុវត្តយ៉ាងពេញលេញនូវគម្រោង "App-Learning on Khmer Rouge History"[6]។ គម្រោង App-Learning on Khmer Rouge History ដែលកើតចេញពីគម្រោងផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការអប់រំយុវជនកម្ពុជា និងសាធារណជនអំពីបទពិសោធន៍ដើមបណ្តឹងរដ្ឋប្បវេណី និងប្រវត្តិសាស្ត្រខ្មែរក្រហម។ គម្រោងនេះរក្សាទុកការចងចាំ និងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិត តាមរយៈការលើកទឹកចិត្តឱ្យមានការសន្ទនាអន្តរជំនាន់រវាងអ្នករស់រានមានជីវិត និងយុវជន ក៏ដូចជាជម្រុញគោលដៅទប់ស្កាត់មិនឱ្យឧក្រិដ្ឋកម្មកើតឡើងសាជាថ្មី។ គម្រោងនេះបានទទួលមូលនិធិ Rei (Rei Foundation Limited) និងសហភាពអឺរ៉ុបក្រោមកម្មវិធី "ការយល់ដឹង

---

[4] ឯកសារ **E465** សាលក្រម សំណុំរឿង ០០២/០២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៤៤៥៤-៤៤៦៧ ផ្នែកសេចក្តីសម្រេច។

[5] ឯកសារ **F71/1/1/8** សេចក្តីសម្រេច ស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ កថាខណ្ឌ ៤៣។

[6] ឧបសម្ព័ន្ធ ១៖ App-learning on Khmer Rouge History ទំព័រ២។

និងការអប់រំអំពីកម្មវិធីប្រវត្តិសាស្ត្រខ្មែរក្រហម - ការគាំទ្រការអភិវឌ្ឍធនធានអប់រំ” តាមរយៈ UNOPS[7]។

5. គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ កម្មវិធីនេះត្រូវបានទាញយកចំនួន៦៨.៤៤១លើក។ ក្រុមការងារផ្សព្វផ្សាយរបស់មជ្ឈមណ្ឌលបុប្ផាណា បានបណ្តុះបណ្តាលគ្រូចំនួន៤៥៦នាក់នៅទូទាំង២៥រាជធានី-ខេត្ត និងសិស្សានុសិស្ស និងសាធារណជនចំនួន ១០១.៦២២នាក់ លើខ្លឹមសារនិងមុខងារនៃកម្មវិធី។ តំណាងមជ្ឈមណ្ឌលបុប្ផាណា ក៏បានបង្ហាញកម្មវិធីនេះជូនដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៩០ នាក់ផងដែរ[8]។

*២.២. គម្រោងទី២៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ*

6. មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដោយសហការជាមួយ សហមេធាវីនាំមុខ និង អង្គភាពគាំពារជនរងគ្រោះ បានបញ្ចប់ការអនុវត្តគម្រោង “ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ”។ គម្រោងនេះផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការអប់រំយុវជនកម្ពុជាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបទពិសោធន៍ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីទប់ស្កាត់កុំឱ្យឧក្រិដ្ឋកម្មកើតឡើងសាជាថ្មីនាពេលខាងមុខ។ គម្រោងនេះបានទទួលមូលនិធិពីសហភាពអឺរ៉ុបតាមរយៈ UNOPS[9]។

7. ក្នុងចំណោមសកម្មភាពជាច្រើនដែល DC-Cam បានអនុវត្តក្រោមគម្រោងនេះរួមមានការអប់រំចល័ត និងវេទិកាតាមថ្នាក់រៀន និងការបណ្តុះបណ្តាលសាស្ត្រាចារ្យនៅតាមសាកលវិទ្យាល័យ[10]។ នៅចន្លោះខែកុម្ភៈ ដល់ ខែមិថុនា ឆ្នាំ២០១៩ ក្រុមការងារ DC-Cam បានបង្រៀនកម្មវិធីសិក្សាអំពីខ្មែរក្រហមដល់សិស្សាសនុសិស្សចំនួន៨៣៤នាក់ នៅទូទាំងខេត្តព្រៃវែង នៅតាមវិទ្យាល័យ និងភូមិ

---

[7] ឧបសម្ព័ន្ធ ១៖ App-learning on Khmer Rouge History ទំព័រ២។

[8] ឧបសម្ព័ន្ធ ១៖ App-learning on Khmer Rouge History ទំព័រ៣។

[9] ឧបសម្ព័ន្ធ ២៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ ទំព័រ៣។

[10] ឧបសម្ព័ន្ធ ២៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ។

ចំនួនប្រាំបី។ វេទិកានេះរួមមានសកម្មភាពតូចៗ ដូចជា បទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ការបញ្ចាំងភាពយន្ត វេទិកាសំណួរ និងចម្លើយ និងការចែកចាយសៀវភៅ[11]។ ចំពោះវគ្គបណ្តុះបណ្តាលសាស្ត្រាចារ្យនៅតាមសាកលវិទ្យាល័យ DC-Cam បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា រៀបចំសន្និសីទស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅសកលវិទ្យាល័យ ក្រោមប្រធានបទ "អំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅក្នុងប្រវត្តិសាស្ត្រពិភពលោក" នៅវិចិត្រសាលសិល្បៈសហសម័យ ស្ពឹកទិវ្ទ នៃវិទ្យាស្ថានជាតិអប់រំកាលពីថ្ងៃទី១-៣ ខែមេសា ឆ្នាំ២០១៩។ ដើមបណ្តឹងរដ្ឋប្បវេណីពីររូបបានចែករំលែកបទពិសោធន៍របស់ពួកគេនៅក្នុងរបបខ្មែរក្រហម[12]។

8. សាស្ត្រាចារ្យ និងអ្នកជំនាញជាច្រើនបានចូលរួមការពិភាក្សាលើប្រធានបទផ្សេងៗអំពីរបបខ្មែរក្រហម ក្នុងនោះរួមមាន សាស្ត្រាចារ្យ Milton Osbourne និងសាស្ត្រាចារ្យ Piotr Ostazewski ដែលបានចែករំលែកបទពិសោធន៍ជំនាញអំពីអំពើប្រល័យពូជសាសន៍តាមបែបប្រៀបធៀប ចំណែកសហព្រះរាជអាជ្ញាអន្តរជាតិនៃ អ.វ.ត.ក លោក Nikolas Koumjian និងលោកបណ្ឌិត លី សុខឃាង បានពិភាក្សាអំពីដំណើរការផ្សះផ្សាក្រោយសាលាក្តីខ្មែរក្រហម[13]។

## *២.៣. គម្រោងទី៣៖ គម្រោងអណ្តើក៖ គម្រោងអន្តរព័ត៌មានប្រកបដោយភាពច្នៃប្រឌិត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ពលរដ្ឋនៅកម្ពុជា*

9. ដោយមានការគាំទ្រពីសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ សមាគមវប្បធម៌កម្ពុជា-អាល្លឺម៉ង់ និងអង្គការ Khmer Art Action បានអនុវត្តទាំងស្រុងនូវ "គម្រោងអណ្តើក៖ គម្រោងអន្តរព័ត៌មានប្រកបដោយភាពច្នៃប្រឌិត ដើម្បីលើកកម្ពស់យល់ដឹងអំពីប្រវត្តិសាស្ត្រនិងភាពក្លាហានរបស់ពលរដ្ឋនៅកម្ពុជា"។ អង្គការយុវសន្តិភាព ក៏ជាសមាសភាគចូលរួមក្នុងគម្រោងនេះផងដែរ។ គម្រោងនេះមានបញ្ចាំងវីដេអូ ការតាំងពិព័រណ៍រូបភាព និងការសន្ទនាអន្តរជំនាន់ និងបញ្ចូលសកម្មភាពអប់រំនិងវប្បធម៌ពហុប្រព័ន្ធផ្សព្វផ្សាយក្នុងអំឡុងពេលសិក្ខាសាលាជាមួយសិស្ស និស្សិតតាមវិទ្យាល័យនិងសាកលវិទ្យាល័យ។ គម្រោងមានគោលបំណងលើកកម្ពស់សន្តិភាព ការចងចាំ

---

[11] ឧបសម្ព័ន្ធ ២៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ ទំព័រ៣។

[12] ឧបសម្ព័ន្ធ ២៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ ទំព័រ៥។

[13] ឧបសម្ព័ន្ធ ២៖ ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ ទំព័រ៥។

និងការផ្សះផ្សាជាតិ តាមរយៈល្ខោនសហគមន៍ និងការសន្ទនាអន្តរជំនាន់។ គម្រោងនេះផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការអប់រំយុវជនជំនាន់ក្រោយអំពីបទពិសោធន៍នៃដើមបណ្តឹងរដ្ឋប្បវេណី និងបង្កើតវេទិកាសម្រាប់កិច្ចសន្ទនាអន្តរជំនាន់បន្ទាប់ពីការសម្តែងនីមួយៗក្រោមគម្រោងនេះ[14]។ គម្រោងនេះទទួលមូលនិធិទាំងស្រុងពីវិទ្យាស្ថាន Institut für Auslandsbeziehungen (ifa) នៃក្រសួងការបរទេសសហព័ន្ធអាល្លឺម៉ង់ តាមរយៈមូលនិធិ "zivik" និងសហភាពអឺរ៉ុបតាមរយៈ UNOPS[15]។

10. រយៈពេលជាង ១៥ខែ ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៧ គម្រោងនេះ បានអនុវត្តសកម្មភាពបានគ្រប់ ២៥ខេត្ត-ក្រុង ក្នុងប្រទេសកម្ពុជា ដែលមានការសម្តែងសរុបចំនួន ១២៩ នៅតាមសាលានិងសាកលវិទ្យាល័យចំនួន ៣៧កន្លែង ដោយមានវត្តមានសិស្ស និស្សិត ចូលរួមចំនួន ៩៦១៩នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៨៩នាក់[16]។ សិស្ស និស្សិត គឺជាក្រុមគោលដៅចម្បងរបស់គម្រោងនេះ។ ពួកគេបានបង្ហាញពីចំណេះដឹង និងការចាប់អារម្មណ៍កាន់តែច្រើនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ពួកគេក៏បានបង្ហាញពីការយល់ដឹងអំពីបញ្ហាមនុស្សធម៌និងសង្គម ហើយបានបង្ហាញពីភាពជឿជាក់ក្នុងការដោះស្រាយបញ្ហានៅក្នុងសង្គមទំនើប ដោយអនុញ្ញាតឱ្យមានការចូលរួមក្នុងសង្គមស៊ីវិល[17]។

11. គម្រោងបានអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ដើម្បីចូលរួមនៅក្នុងការការសន្ទនាអន្តរជំនាន់ជាមួយយុវជនកម្ពុជា។ ដើមបណ្តឹងរដ្ឋប្បវេណីអាចចែករំលែកបទពិសោធន៍របស់ពួកគាត់រួមទាំងការខូចខាតនិងការឈឺចាប់របស់ពួកគាត់។ ការសន្ទនាអន្តរជំនាន់បានទទួលស្គាល់ពីការឈឺចាប់និងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីពីសំណាក់យុវជនកម្ពុជា ដោយអាចទាក់ទាញពួកគេឱ្យមានចំណាប់អារម្មណ៍និងជឿទៅលើរឿងរ៉ាវអតីតកាល ថាពិតជាកើតមានអំពើឃោឃៅបែបនេះបានកើតឡើងមែន[18]។

### *២.៤ គម្រោងទី៤៖ គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម*

---

[14] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ២៣។

[15] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ២៥។

[16] ឧបសម្ព័ន្ធ ៣៖ របាយការណ៍គម្រោងអណ្តើក៖ ល្ខោនសហគមន៍និងការសន្ទនាអន្តរជំនាន់ កម្ពុជា ២០១៦-២០១៨ ទំព័រ ៣។

[17] ឧបសម្ព័ន្ធ ៣៖ របាយការណ៍គម្រោងអណ្តើក៖ ល្ខោនសហគមន៍និងការសន្ទនាអន្តរជំនាន់ កម្ពុជា ២០១៦-២០១៨ ទំព័រ ៣។

[18] ឧបសម្ព័ន្ធ ៣៖ របាយការណ៍គម្រោងអណ្តើក៖ ល្ខោនសហគមន៍និងការសន្ទនាអន្តរជំនាន់ កម្ពុជា ២០១៦-២០១៨ ទំព័រ ៣។

12. ដោយសហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ សមាគមវប្បធម៌កម្ពុជា-អាល្លឺម៉ង់ បានអនុវត្តទាំងស្រុងនូវ "គម្រោងប្រព័ន្ធផ្សព្វផ្សាយសហគមន៍៖ ប្រជាជនចាម និងខ្មែរក្រហម"[19]។ ជាពិសេស គម្រោងផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិចាម គ្រួសារពួកគេ និងយុវជន តាមរយៈការអប់រំដល់សាធារណជនអំពីបទពិសោធន៍របស់សហគមន៍ជនជាតិចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្រោមគម្រោងនេះ ផលិតករវ័យក្មេង អ្នកថតរូប និងអ្នកស្រាវជ្រាវមកពីសហគមន៍ជនជាតិចាមផលិតរឿងផ្ទាល់ខ្លួនរបស់ ដើមបណ្តឹងរដ្ឋប្បវេណីជនជាតិចាមទៅជាខ្សែភាពយន្តចំនួនពីរ។ ខ្សែភាពយន្តឯកសារនេះបង្ហាញដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងរួមបញ្ចូលកូនៗរបស់ពួកគេក្នុងការអភិវឌ្ឍ និងផលិតគម្រោងនេះឡើង[20]។ គម្រោងនេះបានមូលនិធិទាំងស្រុងតាមរយៈស្ថានទូតស្វីសនៅទីក្រុងបាងកក និងមូលនិធិ Heinrich Böll[21]។

13. ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០១៧ គម្រោងនេះបានផលិតវីដេអូឯកសារចំនួនពីរនិងថតការធ្វើសក្ខីកម្ម និងការធ្វើបទសម្ភាសន៍ជាច្រើន។ ការតាំងពិព័រណ៍រូបភាពនិងការបញ្ចាំងកុនត្រូវបានធ្វើឡើងនៅ Meta House[22]។ ក្នុងឆ្នាំ២០១៨ មានព្រឹត្តការណ៍ចំនួន១៦ ត្រូវបានរៀបចំឡើងនៅខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តកំពង់ឆ្នាំង និងទីក្រុងភ្នំពេញ ដែលមានអ្នកចូលរួមប្រហែល៨00នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១២នាក់។ ព្រឹត្តការណ៍ទាំងនោះបានរៀបចំឡើងនៅតាមសាលាចំនួន ២ នៅសាកលវិទ្យាល័យចំនួន ៤ នៅ Meta House និងនៅតាមសហគមន៍ចំនួន២ ដែលជាទីតាំងដែលបានថតខ្សែវីដេអូ គឺនៅស្វាយឃ្លាំង (ឃុំត្បូង) និងឬស្សីកែវ ឬគីឡូម៉ែត្រលេខ៩ (ភ្នំពេញ)[23]។

14. វីដេអូឯកសារក្នុងគម្រោងនេះ មិនត្រឹមតែបានផ្តួចផ្តើមអំពីការសន្ទនាអន្តរជំនាន់ប៉ុណ្ណោះនោះទេ ថែមទាំងអំពីការសន្ទនាអន្តរសាសនាផងដែរ។ គម្រោងនេះបានជម្រុញឱ្យមានការពិភាក្សាអំពីការខូចខាតនិងការឈឺចាប់របស់ប្រជាជនចាម រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិចាម។ ជាពិសេសគម្រោងនេះបានជួយអប់រំដល់សិស្ស និស្សិត រួមទាំងសិស្ស និស្សិត ដែលកាន់សាសនាអ៊ីស្លាម និងសិស្ស និស្សិតដែលកាន់សាសនាព្រះពុទ្ធ អំពីអំពើឃោរឃៅរបស់ខ្មែរក្រហម[24]។

---

[19] ឧបសម្ព័ន្ធ ៤៖ របាយការណ៍ឆ្នាំ ២០១៨ ប្រជាជនចាម និងខ្មែរក្រហម។

[20] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ២៧។

[21] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ២៩។

[22] ឧបសម្ព័ន្ធ ៤៖ របាយការណ៍ឆ្នាំ ២០១៨ ប្រជាជនចាម និងខ្មែរក្រហម ទំព័រ ៤។

[23] ឧបសម្ព័ន្ធ ៤៖ របាយការណ៍ឆ្នាំ ២០១៨ ប្រជាជនចាម និងខ្មែរក្រហម ទំព័រ ៤។

[24] ឧបសម្ព័ន្ធ ៤៖ របាយការណ៍ឆ្នាំ ២០១៨ ប្រជាជនចាម និងខ្មែរក្រហម ទំព័រ ១៨។

*២.៥ គម្រោងទី៥៖ ផ្កាស្លាក្រោមអង្គការ*

15. អង្គការក្ដីករុណា វិទ្យាស្ថានសិល្បៈខ្មែរ មជ្ឈមណ្ឌលបុប្ផាណា និងអង្គការចិត្តសង្គមអន្តរវប្បធម៌ បានអនុវត្តទាំងស្រុងនូវគម្រោង "ផ្កាស្លាក្រោមអង្គ"[25]។ គម្រោងនេះបានផលិតរបាំបុរាណ និងការតាំងពិព័រណ៍ ទាក់ទងនឹងការកំណត់បទបញ្ញានៃអាពាហ៍ពិពាហ៍ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គម្រោងនេះរួមបញ្ចូលការសម្ដែងជាសាធារណៈ និងការសន្ទនានៅតាមសហគមន៍ និងអន្តរជំនាន់ ដើម្បីលើកកម្ពស់ការពិភាក្សាជាសាធារណៈ និងការយល់ដឹងអំពីការកំណត់របៀបរបបរៀបចំអាពាហ៍ពិពាហ៍ក្រោមរបបខ្មែរក្រហម។ គម្រោងនេះផ្ដល់អត្ថប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីតាមរយៈការជួសជុលការខូចខាត ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរងដោយសារការកំណត់បទបញ្ញានៃអាពាហ៍ពិពាហ៍។ គម្រោងនេះក៏លើកទឹកចិត្តឱ្យមានការពិភាក្សា ជាហេតុនាំដល់ការលើកកម្ពស់ការយល់ដឹងកាន់តែធំធេងជាងមុនអំពីបទពិសោធន៍ទាំងនេះ។ គម្រោងនេះទទួលមូលនិធិទាំងស្រុងពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ស្វីស ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់តាមរយៈ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)[26]។

16. អង្គការអនុវត្ត បានធ្វើសកម្មភាពជាច្រើនចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៩។ សកម្មភាពថ្មីៗបំផុតគឺនៅចន្លោះខែឧសភា និងខែមិថុនា ឆ្នាំ២០១៩ ដែលរួមមានការតាំងពិព័រណ៍ចំនួនពីរ និងវេទិកាសន្ទនាអន្តរជំនាន់ ដែលត្រូវបានអនុវត្តនៅក្នុងខេត្តរតនគិរី និងកំពង់ឆ្នាំង។ សកម្មភាពនេះមានការចូលរួមយ៉ាងសកម្មពីសាលាខេត្តពាក់ព័ន្ធ សហមេធាវីនាំមុខជាតិ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នករស់រានមានជីវិត លោកគ្រូ អ្នកគ្រូ និងយុវជន។ អ្នកចូលរួមទទួលបានព័ត៌មានថ្មីៗអំពីដំណើរការនីតិវិធីនៅ អ.វ.ត.ក ហើយបានចូលរួមការតាំងពិពណ៌ វេទិកាមហោស្រព និងការសន្ទនាអន្តរជំនាន់[27]។

*២.៦ គម្រោងទី៦៖ សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហម*

---

[25] ឧបសម្ព័ន្ធ ៥៖ អង្គការក្ដីករុណា - របាយការណ៍សង្ខេបប្រចាំឆ្នាំ (ថ្ងៃទី១៥ ខែកុម្ភៈ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩)។

[26] បណ្ដឹងទាមទារចុងក្រោយ កថាខណ្ឌ ៣២។

[27] ឧបសម្ព័ន្ធ ៥៖ អង្គការក្ដីករុណា - របាយការណ៍សង្ខេបប្រចាំឆ្នាំ (ថ្ងៃទី១៥ ខែកុម្ភៈ ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩) ទំព័រ ៥។

17. អង្គការក្ដីករុណា ដោយមានការគាំទ្រពីសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានអនុវត្តទាំងស្រុងនូវគម្រោង "សំឡេងពីជនជាតិភាគតិច៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហម"[28]។ គម្រោងនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្ដល់ផលប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីជនជាតិចាម និងជនជាតិវៀតណាមតាមរយៈការចងក្រងឯកសារ និងបង្ហាញបទពិសោធន៍របស់ពួកគេក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងផ្ដល់ឱកាសឱ្យមានកិច្ចសន្ទនាអន្តរជំនាន់។ គម្រោងនេះលើកកម្ពស់ការយល់ដឹងអំពីមូលហេតុ និងផលវិបាកនៃអំពើហិង្សាលើជនជាតិភាគតិច និងការរើសអើងប្រឆាំងដើមបណ្ដឹងរដ្ឋប្បវេណីជនជាតិវៀតណាមតាមរយៈការតាំងពិព័រណ៍ចល័ត កិច្ចសន្ទនាអន្តរជំនាន់ ការបោះពុម្ពរឿងប្រលោមលោកអមទៅដោយរូបភាព និងវេទិកាមហោស្រព។ គម្រោងនេះបានទទួលមូលនិធិទាំងស្រុងពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់ តាមរយៈសេវាសន្តិភាពសម្រាប់ពលរដ្ឋ (ZFD) នៃ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH និងស្ថានទូតស្វីសនៅទីក្រុងបាងកក[29]។

18. អង្គការក្ដីករុណា បានអនុវត្តសកម្មភាពជាច្រើនតាំងពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៩។ សកម្មភាពថ្មីៗបំផុតគឺនៅចន្លោះខែកញ្ញា ដល់ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅពេលដែលអង្គការក្ដីករុណា បានធ្វើទស្សនកិច្ចនៅខេត្តពោធិសាត់ ខេត្តកណ្ដាល និងខេត្តស្វាយរៀង ដើម្បីរៀបចំការតាំងពិពណ៌ចល័ត និងវេទិកាមហោស្រព និងបានសម្របសម្រួលកិច្ចសន្ទនារវាងដើមបណ្ដឹងរដ្ឋប្បវេណី និស្សិត និងអ្នករស់រានមានជីវិតផ្សេងទៀត។ កិច្ចសន្ទនាបើកចំហបានបើកឱ្យមានឱកាសបង្ហាញអំពីការទទួលស្គាល់ និងការអាណិតអាសូរដល់ក្រុមជនជាតិភាគតិច[30]។

### *២.៧ គម្រោងទី៧៖ រឿងរ៉ាវដែលមិនធ្លាប់បានគេដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានចូលរួមក្នុងសំណុំរឿង ០០២/០២ នៅ អ.វ.ត.ក*

---

[28] ឧបសម្ព័ន្ធ ៦៖ របាយការណ៍គម្រោង៖ សំឡេងពីជនជាតិភាគតិច (VEM)៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហម ទំព័រ ១៣។

[29] បណ្ដឹងទាមទារចុងក្រោយ កថាខណ្ឌ ៣៥។

[30] ឧបសម្ព័ន្ធ ៦៖ របាយការណ៍គម្រោង៖ សំឡេងពីជនជាតិភាគតិច (VEM)៖ ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងរបបខ្មែរក្រហម ទំព័រ ៤។

19. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) បានអនុវត្តទាំងស្រុងនូវគម្រោង “រឿងរ៉ាវដែលមិនធ្លាប់បានគេដឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងសំណុំរឿង 00២/0២ នៅ អ.វ.ត.ក”។ ប៉ុន្តែ អង្គការនេះ ត្រូវបានរំលាយ ដោយរៀបចំឡើងវិញក្រោមគណៈគ្រប់គ្រងថ្មី។ គណៈគ្រប់គ្រងថ្មីបានជូនដំណឹងដល់សហមេធាវីនាំមុខថា ពួកគេមិនមានរបាយការណ៍ ឬ សម្ភារៈនៃគម្រោងសំណាងនេះទេ។ គម្រោងនេះបានទទួលមូលនិធិទាំងស្រុងពីមូលនិធិ Heinrich Böll[31]។

20. ដូចបានលើកឡើងនៅក្នុងបណ្តឹងទាមទារចុងក្រោយ គម្រោងនេះបានផលិតសៀវភៅអមដោយរូបភាពអំពីរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានឆ្លងកាត់ឧក្រិដ្ឋកម្មទាំងនោះ និងប្រធានបទដែលបានជំនុំជម្រះក្នុងសំណុំរឿង 00២/0២។ រឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានប្រមូលចងក្រងដំណើររឿងតាំងពីខែមិថុនា ឆ្នាំ២០១៥ និងបានបញ្ចប់ការផលិតសៀវភៅទាំងនេះក្នុងខែមិថុនា ឆ្នាំ២០១៦[32]។ នៅពេលដែលដាក់បណ្តឹងទាមទារចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣0រូប ត្រូវបានសម្ភាសន៍ ហើយរឿងរ៉ាវរបស់ពួកគាត់ត្រូវបានបកប្រែជាភាសាអង់គ្លេស។ នៅចុងបញ្ចប់នៃការធ្វើបទសម្ភាសន៍ ដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួម បានបង្ហាញពីការពេញចិត្តក្នុងករណីដែលរឿងរ៉ាវរបស់ពួកគាត់ត្រូវបានបោះពុម្ពផ្សាយ ជាពិសេស ដោយសារតែរឿងរ៉ាវទាំងនោះ ជួយឱ្យយុវជននៅក្នុងសហគមន៍របស់ពួកគាត់យល់ដឹងនូវអ្វីដែលបានកើតឡើងក្រោមរបបខ្មែរក្រហម។ សៀវភៅចំនួន ៥00ក្បាល ត្រូវបានបោះពុម្ពឡើង[33]។

21. ក្រោយពេលដាក់បណ្តឹងទាមទារចុងក្រោយ ជំហ៊ានបន្ទាប់គឺ អង្គការ CHRAC នឹងធ្វើការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ ដើម្បីចែកសៀវភៅដែលបានបោះពុម្ពជូនដល់ដើមបណ្តឹងរដ្ឋប្បវេណី និងដល់គ្រឹះស្ថានអប់រំ[34]។ សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានធ្វើការជាមួយ អង្គការ CHRAC ក្នុងការងារចែកសៀវភៅនេះដោយអនុវត្តចប់ទាំងស្រុង។

*២.៨ គម្រោងទី៨៖ ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀងស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ២០១៦*

[31] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៤0។

[32] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៣៨។

[33] ឯកសារ E457/6/2/1.1.7 ឧបសម្ព័ន្ធ ៧.៦៖ ពត៌មានស្តីពីការអនុវត្ត ដែលទទួលបានពីអង្គការ CHRAC ទំព័រ ១-២។

[34] ឯកសារ E457/6/2/1.1.7 ឧបសម្ព័ន្ធ ៧.៦៖ ពត៌មានស្តីពីការអនុវត្ត ដែលទទួលបានពីអង្គការ CHRAC ទំព័រ ១-២។

22. កម្មវិធីអភិវឌ្ឍធនធានយុវជន (YRDP) បានអនុវត្តទាំងស្រុងនូវគម្រោង "ពេលវេលាដែលត្រូវចងចាំ៖ ការប្រកួតប្រជែងរបស់យុវជនក្នុងការតាក់តែងចម្រៀងស្តីពីការចងចាំនៅកម្ពុជា ឆ្នាំ២០១៦" [35]។ គោលបំណងនៃគម្រោងនេះគឺដើម្បីរួមចំណែកដល់ដំណើរការផ្សះផ្សានៅកម្ពុជា។ ការប្រកួតប្រជែងការតាក់តែងចម្រៀង បានផ្តល់ឱកាសដល់តន្ត្រីករវ័យក្មេងផ្ទុះបញ្ចាំងអំពីសោកនាដកម្មពីអតីតកាល យកមកបង្ហាញតាមរយៈបទចម្រៀង និងការច្នៃប្រឌិតផ្នែកសិល្បៈ។ តាមរយៈខ្លឹមសារបទចម្រៀង និងសាច់ភ្លេង យុវជនទទួលស្គាល់ទុក្ខលំបាករបស់មនុស្សជំនាន់មុន[36]។ គម្រោងនេះទទួលមូលនិធិទាំងស្រុងពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់ តាមរយៈសេវាសន្តិភាពសម្រាប់ពលរដ្ឋ (ZFD) នៃ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH[37]។

23. ដោយមានការគាំទ្រពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ[38] សិក្ខាសាលាពិគ្រោះយោបល់ចំនួន ០៣ បានធ្វើឡើងចាប់ពីខែមីនា ដល់ ខែឧសភា ឆ្នាំ២០១៦ ដែលមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១២នាក់ និងយុវជនចំនួន ៧៩នាក់ចូលរួម។ យុទ្ធនាការផ្សព្វផ្សាយបានធ្វើឡើងចាប់ពីខែកក្កដា ដល់ ខែធ្នូតាមរយៈការប្រើប្រាស់បណ្តាញហ្វេសប៊ុក។ ក្នុងចំណោមបេក្ខជនចំនួន ៤០នាក់ មានបេក្ខជន ១០នាក់ត្រូវបានជ្រើសរើសយកមកច្រៀង ក្នុងនោះ ក្នុងចំណោម១០នាក់ មានបេក្ខជន ០៥នាក់ ត្រូវបានជ្រើសរើសចូលរួមសម្តែង និងទទួលបានការបង្វឹក[39]។ ការប្រគំតន្ត្រីចុងក្រោយបានធ្វើឡើងកាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៦ នៅចំពោះមុខទស្សនិកជនជិត ៤០០នាក់[40]។ គណៈកម្មាធិការរួមមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០២រូប និងអ្នកនៅរស់ចំនួន ០៣រូបផ្សេងទៀត[41]។ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងដូចគ្នាថា ពួកគេមានការចាប់អារម្មណ៍ក្តុកក្តួលតាមរយៈការសម្តែងដែលយុវជនទទួលស្គាល់ការឈឺចាប់របស់ពួកគេ ខណៈយុវជនបានបង្ហាញអារម្មណ៍ថា ពួកគេបានស្វែងយល់

---

[35] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៤១។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ៧៖ ការប្រកួតប្រជែងក្នុងការតាក់តែងចម្រៀងស្តីពីការចងចាំ។

[36] ឧបសម្ព័ន្ធ ៧៖ ការប្រកួតប្រជែងក្នុងការតាក់តែងចម្រៀងស្តីពីការចងចាំ ទំព័រ ១។

[37] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៤៣។

[38] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៤១។

[39] ឧបសម្ព័ន្ធ ៧៖ ការប្រកួតប្រជែងក្នុងការតាក់តែងចម្រៀងស្តីពីការចងចាំ ទំព័រ ១។

[40] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៤១។

[41] ឧបសម្ព័ន្ធ ៧៖ ការប្រកួតប្រជែងក្នុងការតាក់តែងចម្រៀងស្តីពីការចងចាំ ទំព័រ ២។

កាន់តែច្រើនជាងមុនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបានយល់កាន់តែច្បាស់អំពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី[42]។

*២.៩ គម្រោងទី៩៖ ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់*

24. អង្គការយុវសន្តិភាព (YFP) និងវិទ្យាស្ថានសន្តិភាពកម្ពុជា (PIC) បានអនុវត្តទាំងស្រុងនូវគម្រោង "ផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់"[43]។ ការតាំងពិព័រណ៍ផ្ទាំងគំនូរដើម្បីការចងចាំនៃមន្ទីរសន្តិសុខត្រូវបានបង្កើតឡើងជាមួយនិស្សិតសាកលវិទ្យាល័យ និងដោយមានការពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី[44]។ កូនសៀវភៅមួយក្បាលត្រូវបានផលិតឡើងដើម្បីរំលឹកដល់ដំណើរការនៃការបង្កើតផ្ទាំងគំនូរដើម្បីការចងចាំ[45]។ គម្រោងនេះបានទទួលមូលនិធិទាំងស្រុងពីសម្ព័ន្ធអន្តរជាតិនៃ International Coalition of Sites of Conscience [46]។

25. នៅក្រោមគម្រោងនេះ អ្នកអនុវត្តបានបណ្តុះបណ្តាលនិស្សិតសាកលវិទ្យាល័យចំនួន ១១នាក់ ដើម្បីចងក្រងប្រវត្តិសាស្ត្រផ្ទាល់មាត់អំពីក្រាំងតាចាន់ តាមរយៈការកសាងសមត្ថភាពលើប្រវត្តិសាស្ត្រផ្ទាល់មាត់ ការចងចាំ និងបច្ចេកទេសធ្វើសម្ភាស[47]។ អ្នកអនុវត្តក៏បានចូលរួមជាមួយមនុស្ស ១៦០ នាក់ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី អ្នករស់រានមានជីវិត យុវជននៅតាមសហគមន៍ និងសិស្សានុសិស្សនៅតាមវិទ្យាល័យដើម្បីអភិវឌ្ឍគម្រោង និងកសាងការយល់ដឹង។ គម្រោងនេះត្រូវបានអនុវត្តនៅចន្លោះខែកក្កដា និងខែធ្នូ ឆ្នាំ២០១៦ ដោយបានឆ្លើយតបទៅនឹងគោលបំណងនៃការចងចាំ ការទទួលស្គាល់អំពីពន្ធសនកម្ម និងការរងទុក្ខសោក ការសន្ទនាអន្តរជំនាន់ និងការចែករំលែកបទពិសោធន៍[48]។

---

[42] ឧបសម្ព័ន្ធ ៧៖ ការប្រកួតប្រជែងក្នុងការតាក់តែងចម្រៀងស្តីពីការចងចាំ ទំព័រ ២។

[43] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៩៥។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ៨៖ របាយការណ៍ចុងក្រោយស្តីពីគម្រោងផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់ ទំព័រ ៥។

[44]បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៩៥។

[45] ឧបសម្ព័ន្ធ ៩៖ របាយការណ៍ចុងក្រោយស្តីពីគម្រោងផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់។

[46] ឧបសម្ព័ន្ធ ៨៖ របាយការណ៍ចុងក្រោយស្តីពីគម្រោងផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់ ទំព័រ ១៩។

[47] ឧបសម្ព័ន្ធ ៨៖ របាយការណ៍ចុងក្រោយស្តីពីគម្រោងផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់ ទំព័រ ៥។

[48] ឧបសម្ព័ន្ធ ៨៖ របាយការណ៍ចុងក្រោយស្តីពីគម្រោងផ្ទាំងគំនូរដើម្បីការចងចាំអំពីក្រាំងតាចាន់ ទំព័រ ៥។

*២.១០ គម្រោងទី ១០៖ ការចូលមើលកំណត់ហេតុតុលាការស្តីពីការកាត់ក្តីខ្មែរក្រហម និងសម្ភារៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹង អ.វ.ត.ក (ម.ច.អ.ត)*

26. រាជរដ្ឋាភិបាលកម្ពុជា តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអនុវត្តទាំងស្រុងនូវគម្រោង "ការចូលមើលកំណត់ហេតុតុលាការស្តីពីការកាត់ក្តីខ្មែរក្រហម និងសម្ភារៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹង អ.វ.ត.ក (ម.ច.អ.ត)"[49]។ ម.ច.អ.ត បានបង្កើតបណ្ណាំឯកសារសាធារណៈដោយមិនគិតថ្លៃ ទាក់ទងនឹងដំណើរការនីតិវិធី និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក។ ម.ច.អ.ត ក៏បានធ្វើសកម្មភាពផ្សព្វផ្សាយនៅទូទាំងប្រទេស ដើម្បីលើកកម្ពស់ការយល់ដឹងអំពីអ្វីដែលបានកើតឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ[50]។ គម្រោងនេះបានទទួលមូលនិធិទាំងស្រុងពីរាជរដ្ឋាភិបាលកម្ពុជា។ អគារ ម.ច.អ.ត ត្រូវបានសាងសង់ឡើងតាមរយៈហិរញ្ញប្បទានពីស្ថានទូតជប៉ុន[51]។

27. គម្រោងនេះផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណី ដោយបានផ្តល់លទ្ធភាពជូនពួកគេអាចចូលមើលឯកសារតុលាការពាក់ព័ន្ធនឹងដំណើរការរបស់ អ.វ.ត.ក និងដោយបានជួយសម្រួលដល់ការចូលមើល និងផ្សព្វផ្សាយឯកសារដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារសាធារណៈរបស់តុលាការដល់សាធារណជន និងយុវជនជំនាន់ក្រោយ។ ម.ច.អ.តមិនត្រឹមតែរក្សាទុកឯកសារតុលាការប៉ុណ្ណោះទេ ថែមទាំងឯកសារទាក់ទងនឹងខ្មែរក្រហមដែលទទួលបានពីដៃគូ និងសាធារណជនផងដែរ[52]។ ចំពោះការងារផ្សព្វផ្សាយចាប់ពីឆ្នាំ២០១៧ ដល់ ឆ្នាំ២០២២ ម.ច.អ.តបានផ្សព្វផ្សាយដល់ប្រជាជនចំនួន ៣០.៥២៣នាក់ និងបានចុះតាមសាលារៀនសរុបចំនួន ១៧៥ទីតាំងនៅទូទាំងប្រទេស[53]។ លើសពីនេះ ម.ច.អ.តបានរៀបចំ និងចូលរួមសិក្ខាសាលាសរុបចំនួន ៦៥ ស្តីពីប្រវត្តិសាស្ត្រខ្មែរក្រហម[54]។

---

[49] ឧបសម្ព័ន្ធ ១០៖ របាយការណ៍ស្តីពីវឌ្ឍនភាពការងារ ម.ច.អ.ត។

[50] ឧបសម្ព័ន្ធ ១០៖ របាយការណ៍ស្តីពីវឌ្ឍនភាពការងារ ម.ច.អ.ត។

[51] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៤៩។

[52] ឧបសម្ព័ន្ធ ១០៖ របាយការណ៍ស្តីពីវឌ្ឍនភាពការងារ ម.ច.អ.ត ទំព័រ ៣។

[53] ឧបសម្ព័ន្ធ ១០៖ របាយការណ៍ស្តីពីវឌ្ឍនភាពការងារ ម.ច.អ.ត ទំព័រ ៤។

[54] ឧបសម្ព័ន្ធ ១០៖ របាយការណ៍ស្តីពីវឌ្ឍនភាពការងារ ម.ច.អ.ត ទំព័រ ៤។

*២.១១ គម្រោងទី ១១៖ ការព្យាបាល និងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម*

28. អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា (TPO) និងអង្គការក្ដីករុណា បានអនុវត្តទាំងស្រុងនូវគម្រោង "ការព្យាបាល និងការផ្សះផ្សាសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម"[55]។ គម្រោងនេះផ្ដល់ការព្យាបាលសុខភាពផ្លូវចិត្ត អន្តរាគមន៍ដោយប្រើការរៀបរាប់ការពិត និងការផ្សះផ្សា និងការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិកគម្រោងនៅក្នុងសហគមន៍គោលដៅ។ គម្រោងនេះបានទទួលមូលនិធិទាំងស្រុងពី USAID[56]។

29. គោលដៅចម្បងនៃគម្រោងគឺដើម្បីលើកកម្ពស់ការព្យាបាលការប៉ះទង្គិចផ្លូវចិត្ត សម្រាប់បុគ្គល និងសហគមន៍ដែលធ្លាប់ទទួលរងការធ្វើទារុណកម្មក្រោមរបបខ្មែរក្រហម ក៏ដូចជាពង្រឹងភាពធន់ និងលើកកំពស់សមត្ថភាពរបស់អ្នករស់រានមានជីវិត សម្រាប់ការដោះស្រាយជម្លោះដោយសន្តិវិធី[57]។ គម្រោងនេះត្រូវបានអនុវត្តក្នុងសហគមន៍ចំនួន ១៥ ក្នុងខេត្ត ចំនួន ១៥ នៅទូទាំងប្រទេស[58]។

30. លទ្ធផលនៃគម្រោងបានបង្ហាញថា អ្នករស់រានមានជីវិតពីការធ្វើទារុណកម្ម ប្រមាណ ៦0% នៃមានសុខមាលភាពប្រសើរជាងមុន និងបានពង្រឹងភាពធន់ និងយុទ្ធសាស្ត្រដោះស្រាយតាមរយៈការទទួលបានសេវាព្យាបាលការប៉ះទង្គិចផ្លូវចិត្ត និងដំណើរការផ្សះផ្សា។ ក្រុមទាំងនោះ ដែលទទួលរងផលប៉ះពាល់ដោយការធ្វើទារុណកម្ម មានការយល់ដឹងច្រើនជាងមុនអំពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តពីអតីតកាល និងមានអារម្មណ៍កាន់តែអាណិតអាសូរចំពោះអ្នកនៅរស់រានមានជីវិតផ្សេងទៀត។ ចំពោះការកសាងសមត្ថភាព គិតត្រឹមចុងឆ្នាំ២0១៨ គ្រូពេទ្យ និងអ្នកព្យាបាលចលនារបស់ TPO ចន្លោះ ៧0-៨0% បានបង្កើនសមត្ថភាព និងទំនុកចិត្តក្នុងការប្រើជំនាញ "វិធីសាស្ត្រព្យាបាលរួម" របស់ TPO ក្នុងការសម្រួលអន្តរាគមន៍ផ្លូវចិត្តប្រមាណ ៣0%[59]។

---

[55] ឧបសម្ព័ន្ធ ១១៖ របាយការណ៍វាយតម្លៃ៖ ការព្យាបាល និងការផ្សះផ្សាសម្រាប់ជនរងគ្រោះទារុណកម្មនៃការប៉ះទង្គិចផ្លូវចិត្តក្នុងរបបខ្មែរក្រម។

[56] បណ្ដឹងទាមទារចុងក្រោយ កថាខណ្ឌ ៥៣។

[57] ឧបសម្ព័ន្ធ ១១៖ របាយការណ៍វាយតម្លៃ៖ ការព្យាបាល និងការផ្សះផ្សាសម្រាប់ជនរងគ្រោះទារុណកម្មនៃការប៉ះទង្គិចផ្លូវចិត្តក្នុងរបបខ្មែរក្រម ទំព័រ ៥។

[58] ឧបសម្ព័ន្ធ ១១៖ របាយការណ៍វាយតម្លៃ៖ ការព្យាបាល និងការផ្សះផ្សាសម្រាប់ជនរងគ្រោះទារុណកម្មនៃការប៉ះទង្គិចផ្លូវចិត្តក្នុងរបបខ្មែរក្រម ទំព័រ ១៥។

[59] ឧបសម្ព័ន្ធ ១១៖ របាយការណ៍វាយតម្លៃ៖ ការព្យាបាល និងការផ្សះផ្សាសម្រាប់ជនរងគ្រោះទារុណកម្មនៃការប៉ះទង្គិចផ្លូវចិត្តក្នុងរបបខ្មែរក្រម ទំព័រ ៥។

*២.១២ គម្រោងទី១២៖ ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច*

31. អង្គការការពារសិទ្ធិជនជាតិភាគតិច (“MIRO”) បានអនុវត្តទាំងស្រុងនូវគម្រោង “ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច” នៅចន្លោះខែកក្កដា និងខែធ្នូ ឆ្នាំ២០១៦[60]។ គម្រោងនេះរួមមានមានគម្រោងសាកល្បងអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋ ពិធីពិគ្រោះយោបល់សហគមន៍ ការផលិតសម្ភារផ្សព្វផ្សាយជាភាសាដែលសហគមន៍អាចយល់បាន និងសិក្ខាសាលាផ្សព្វផ្សាយ និងអប់រំនៅមូលដ្ឋានសហគមន៍ចំនួនបី ដែលធ្វើឡើងនៅក្នុងសហគមន៍ដែលដើមបណ្តឹងរដ្ឋប្បវេណីរស់នៅ[61]។ គម្រោងនេះបានទទួលមូលនិធិទាំងស្រុងពីក្រសួងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍អាល្លឺម៉ង់ តាមរយៈ Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH[62]។

32. គម្រោងនេះមានគោលបំណងជួសជុលការខូចខាត ដែលទទួលរងគ្រោះដោយដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការផ្តល់ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាតាមរយៈការស្វែងរកកិច្ចសហការជាមួយកម្មវិធីសង្គមស៊ីវិលផ្សេងទៀត ដែលកំពុងចូលរួមក្នុងការផ្សព្វផ្សាយសហគមន៍គោលដៅ[63]។ អ្នកទទួលផលពីកម្មវិធីនេះ រួមមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៩រូប ដែលបានចូលរួមកិច្ចពិគ្រោះយោបល់ និងសិក្ខាសាលាផ្សព្វផ្សាយនៅតាមសហគមន៍កូនៗ និងចៅៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណី រួមជាមួយសមាជិកក្នុងសហគមន៍សរុបចំនួន ៩០នាក់ ដែលបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយនៅមូលដ្ឋានសហគមន៍ចំនួនបី[64]។

---

[60] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៥៦។

[61] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៥៦។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ១១៖ របាយការណ៍បញ្ចប់គម្រោងអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច ទំព័រ ២។

[62] បណ្តឹងទាមទារចុងក្រោយ កថាខណ្ឌ ៥៨។

[63] ឧបសម្ព័ន្ធ ១២៖ របាយការណ៍បញ្ចប់គម្រោងអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច ទំព័រ ១-២។

[64] ឧបសម្ព័ន្ធ ១២៖ របាយការណ៍បញ្ចប់គម្រោងអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច ទំព័រ ៤។

*២.១៣ គម្រោងទី១៣៖ ការលើកកម្ពស់សុខភាព និងសុខុមាលភាពផ្លូវចិត្ត និងការកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការកាត់ផ្តាច់ពីសង្គមនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរាដែលងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា*

33. អង្គការ HelpAge កម្ពុជា បានអនុវត្តទាំងស្រុងនូវគម្រោង "លើកកម្ពស់សុខភាព និងសុខុមាលភាពផ្លូវចិត្ត និងការកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការកាត់ផ្តាច់ពីសង្គមនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរាដែលងាយរងគ្រោះ នៅក្នុងប្រទេសកម្ពុជា"[65]។ គម្រោងនេះជួយដើមបណ្តឹងរដ្ឋប្បវេណីចាស់ជរា តាមរយៈការបង្កើនលទ្ធភាពទទួលបានសេវាថែទាំសុខភាពផ្លូវកាយ និងផ្លូវចិត្ត ដោយបង្កើតកន្លែងផ្តល់សេវាសុខភាពចល័ត ដើម្បីផ្តល់ការថែទាំ និងការពិនិត្យសុខភាពបឋមជាមូលដ្ឋាន និងដើម្បីផ្តល់ការអប់រំសុខភាពផ្លូវចិត្តនៅថ្នាក់សហគមន៍។ គម្រោងនេះក៏បណ្តុះបណ្តាលបុគ្គលិកពេទ្យ និងអ្នកស្ម័គ្រចិត្ត និងពង្រឹកសមត្ថភាពបណ្តាញសមាគមមនុស្សចាស់ (OPA) ដើម្បីឈានទៅដល់ដើមបណ្តឹងរដ្ឋប្បវេណី និងសហគមន៍គោលដៅ។

34. គម្រោងនេះ បានស្វែងរកការបង្កើតមូលនិធិក្នុងគោលដៅបង្កើនប្រាក់ចំណូលរបស់សមាជិករបស់ OPA។ អង្គជំនុំជម្រះសាលាដំបូងមិនឯកភាពចំពោះចំណុចនេះឡើយ ដោយសារវាមានទម្រង់ជាលក្ខណៈបុគ្គល គឺការបង់ប្រាក់។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាដំបូងបានឯកភាពទៅលើផ្នែកនៃការថែទាំសុខភាពនៅក្នុងគម្រោងនេះ ដូចដែលបានរៀបរាប់ជូនខាងលើ[66]។ គម្រោងនេះត្រូវបានអនុវត្តចាប់ពីខែធ្នូ ឆ្នាំ២០១៧ ដល់ខែធ្នូ ឆ្នាំ២០១៩[67] ហើយបានទទួលមូលនិធិទាំងស្រុងពីសហភាពអឺរ៉ុបតាមរយៈ UNOPS និងទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ[68]។

35. តាមរយៈលទ្ធផលនៃការអនុវត្តគម្រោង មាន OPAs ចំនួន ៨១ត្រូវបានពង្រឹងដើម្បីជួយសម្រួល និងផ្តល់ការគាំទ្រដល់ការថែទាំសុខភាពសហគមន៍សម្រាប់មនុស្សចាស់ងាយរងគ្រោះយ៉ាងហោចណាស់ ចំនួន ១.៦០០នាក់។ បុគ្គលិកមណ្ឌលសុខភាពចំនួន ២២នាក់ និងបុគ្គលិកក្រុមគាំទ្រសុខភាពភូមិ បានបង្កើនចំណេះដឹងរបស់ខ្លួនអំពីបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តទាក់ទងនឹងភាពចាស់ជរា

---

[65] ឧបសម្ព័ន្ធ ១៣៖ របាយការណ៍វាយតម្លៃរបស់អង្គការ HelpAge កម្ពុជា។

[66] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ កថាខណ្ឌ ៤៤៦៤ ដល់ ៤៤៦៥។

[67] ឧបសម្ព័ន្ធ ១៣៖ របាយការណ៍វាយតម្លៃរបស់អង្គការ HelpAge កម្ពុជា ទំព័រ ១។

[68] ឧបសម្ព័ន្ធ ១៣៖ របាយការណ៍វាយតម្លៃរបស់អង្គការ HelpAge កម្ពុជា ទំព័រ ១។

ហើយបានផ្តល់សេវាដល់មនុស្សចាស់យ៉ាងហោចណាស់ ២.៤០០នាក់ តាមរយៈកន្លែងសុខភាព និងប្រព័ន្ធបញ្ជូនបន្ត។ សមាជិក OPA ៥០% បានរាយការណ៍ថាបានបង្កើនចំណេះដឹងរបស់ខ្លួនអំពីសិទ្ធិសេរីភាព។ OPAs និងសហព័ន្ធត្រូវបានពិគ្រោះយោបល់ខ្លាំងជាងមុនក្នុងនាមជាភាគីពាក់ព័ន្ធស្របច្បាប់នៅក្នុងវេទិកាគោលនយោបាយជាតិ និងនៅថ្នាក់មូលដ្ឋាន ហើយមានការបង្កើនការយល់ដឹងដល់សាធារណជនជុំវិញបញ្ហាទាក់ទងនឹងសិទ្ធិរបស់ចាស់ជរា[69]។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ | ពេជ្រ អង្គ<br>សហមេធាវីជាតិនាំមុខ | រាជធានីភ្នំពេញ | |
| ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ | Falguni DEBNATH<br>សហមេធាវីអន្តរជាតិនាំមុខ | ទីក្រុងតូរ៉ុនតូ | |

[69] ឧបសម្ព័ន្ធ ១៣៖ របាយការណ៍វាយតម្លៃរបស់អង្គការ HelpAge កម្ពុជា ទំព័រ v។